# ចំណាប់អារម្មណ៍របស់
# លោកស្រី ជឹម ម៉ាណាវ នាយិកាប្រតិបត្តិ អង្គការវិទ្យាស្ថានបើកទូលាយ
# ក្នុងវេទិកាពិភាក្សាស្តីពី
# " ប្រព័ន្ធផ្សព្វផ្សាយនិង ប្រព័ន្ធផ្សព្វផ្សាយសង្គមចូលរួមបញ្ឈប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ "
# ភ្នំពេញ ថ្ងៃទី ៣0 ខែ ឧសភា ឆ្នាំ២០១៣
# សណ្ឋាគារ កាំបូឌីយ៉ាណា

-----------

សូមគោរពលោកជំទាវ **ស៊ី ដេហ្វីន** រដ្ឋលេខាធិការក្រសួងកិច្ចការនារី

សូមគោរពលោក **ប៉ែន សាមិទ្ធិ** ប្រធានក្លឹបអ្នកកាសែតកម្ពុជានិងជាប្រធានក្រុមប្រឹក្សាភិបាលរបស់អង្គការវិទ្យាស្ថានបើកទូលាយ

សូមគោរព លោក **ហេង ពុទ្ធា** អនុប្រធានគណៈកម្មាធិការអង្គារមិនមែនរដ្ឋាភិបាលទទួលបន្ទុកអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី(NGO-CEDAW)

សូមគោរព លោកជំទាវ លោកស្រី អស់លោក ដែលមានវត្តមាននាពេលនេះ

ថ្ងៃនេះអង្គការវិទ្យាស្ថានបើកទូលាយមានកិត្តិយស និងមានសេចក្តីសោមនស្សរីករាយដោយបានទទួល អស់លោក លោកស្រីក្នុង វេទិកាពិភាក្សាស្តីពី"**ប្រព័ន្ធផ្សព្វផ្សាយនិងប្រព័ន្ធផ្សព្វផ្សាយសង្គមចូលរួមបញ្ឈប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ**។ សិក្ខាសាលានេះសហការរៀបចំដោយ ក្រសួងកិច្ចការនារី សម្ព័ន្ធ ភាពជាតិឃុំ សង្កាត់ អង្គការវិទ្យាស្ថានបើកទូលាយអង្គការ Heifer International Cambodia ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC) អង្គការយុវជនខ្មែរ និងការអភិវឌ្ឍសង្គម (KYSD) សមាគមអភិវឌ្ឍន៍សុខភាពប្រជាជន (PHD) ECPAT/CAMBODIA គណៈកម្មាធិការនៃអង្គការមិនរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកអនុសញ្ញាលុបបំបាត់រាល់ ទម្រង់រើសអើង

លើស្ត្រី(NGO-CEDAW)និងសមាគមកាយរិទ្ធិនារីកម្ពុជា ។ តាងនាមអ្នករៀបចំកម្មវិធី នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកស្រី អស់លោក ដែលបានឆ្លៀតពេលមមាញឹកអញ្ជើញមកចូលរួមក្នុងវេទិកាថ្ងៃនេះ។

គោលបំណងវេទិកាគឺផ្តល់ឱកាសឲ្យមានការពិភាក្សាពីសំណាក់ប្រព័ន្ធផ្សព្វផ្សាយនិងអ្នកប្រើ ប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ព្រមទាំងពីសំណាក់ស្ថាប័នផ្សេងៗពីការចូលរួមបញ្ឈប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការពិភាក្សាវាយតម្លៃគម្រោង។

លោកជំទាវ លោកស្រីអស់លោកជាទីគោរព

អំពើហិង្សាទាក់ទងនឹងយេនឌ័រគឺ ជាការរំលោភសិទ្ធិមនុស្សនិងជាទម្រង់នៃការរើសអើង។ អំពើហិង្សាទាក់ទងនឹងយេនឌ័របានឆ្លុះបញ្ចាំងនិងបានពង្រឹងភាពមិនស្មើគ្នារវាងបុរសនិងស្ត្រី។ អំពើហិង្សាទាក់ទងនឹងយេនឌ័រនៅតែជាបញ្ហាសំខាន់នៅប្រទេសកម្ពុជាហើយវាជាផលិតផលនៃវិសមភាពយេនឌ័រនិងទំនៀមទម្លាប់នៅក្នុងរចនាសង្គមកម្ពុជា។ អំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមមានអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត ផ្លូវសេដ្ឋកិច្ចក្តី សកម្មភាពមានដូចជាការវាយតប់ ការជួញដូរជាដើម សុទ្ធសឹងបង្កមហន្តរាយដល់សមភាពយេនឌ័រ និងរារាំងដល់ការសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍសហស្សវត្ស គោលដៅ៣ស្តីពីការផ្តល់ភាពអង់អាចដល់ស្ត្រីនិងការជំរុញសមភាពយេនឌ័រ។

ទោះបីជារាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវច្បាប់ជាច្រើនដើម្បីទប់ស្កាត់និងកាត់បន្ថយអំពើហិង្សាទាក់ទងនិងយេនឌ័រ ក៏អំពើនេះនៅតែកើតមានឡើងច្រើនក្នុងសង្គមកម្ពុជា ។ យើងឃើញថា ឧបសគ្គសំខាន់ក្នុងចំណោម ឧបសគ្គនានាក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងអំពើហិង្សាទាក់ទងនឹងយេនឌ័រគឺការអត់អោនដល់អំពើទាំងនេះពីសំណាក់សង្គមខ្មែរភាគច្រើន។ តាមតួលេខពី The Fact Sheet របស់UNAIDS ( មិថុនា២០១១)បានឲ្យដឹងថាមានបុរស៨៣%និងស្ត្រី៨១%និយាយថាគេមិនបានធ្វើអ្វីទេពេលដឹងថាមានអំពើ ហិង្សាទាក់ទងនិងយេនឌ័រ ក្នុងពេលដែលស្ត្រី៥៣ %ដឹងថាមានបុរសជាប្តីនៅក្នុងភូមិរបស់គេបានប្រើហិង្សាទៅលើប្រពន្ធ។

ជាមួយនិងមធ្យោបាយផ្សេងៗក្នុងការទប់ស្កាត់ អំពើហិង្សាទាក់ទងនិងយេនឌ័រ បច្ចេកវិទ្យា គមនាគមន៍និងព័ត៌មានវិទ្យាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រយុទ្ធប្រឆាំងអំពើហិង្សាលើស្ត្រីអំពើហិង្សាទាក់ទងនិងយេនឌ័រ ។

តើបច្ចេកវិទ្យា សារគមនាគមន៍និងព័ត៌មានវិទ្យាជាអ្វី?

តើបច្ចេកវិទ្យា សារគមនាគមន៍និងព័ត៌មានវិទ្យា អាចធ្វើអ្វីបានខ្លះក្នុងការទប់ស្កាត់និងកាត់បន្ថយអំពើហិង្សាទាក់ទងនិងយេនឌ័រ?

បច្ចេកវិទ្យា សារគមនាគមន៍និងព័ត៌មានវិទ្យាក្នុងអត្ថន័យដ៏ទូលំទូលាយចង់សំដៅទៅលើកុំព្យូទ័រទូរស័ព្ទដៃ វិទ្យុ ទូរទស្សន៍CD digital camera ជាដើម។

បច្ចេកវិទ្យា គមនាគមន៍និងព័ត៌មានវិទ្យាដើរតួនាទីដ៏សំខាន់ក្នុងការប្រយុទ្ធប្រឆាំងអំពើលើស្ត្រី។ មានអង្គការស្ត្រីជាច្រើនបានប្រើប្រាស់ បច្ចេកវិទ្យា គមនាគមន៍និងព័ត៌មានវិទ្យា (ICT) ដូចជាការប្រើ Internet, ទូរទស្សន៍ វិទ្យុ ក៏ដូចជាប្រើប្រាស់ប្រព័ន្ធផ្សព្វ ផ្សាយសង្គម ក្នុងការផ្សព្វផ្សាយអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមមានដូចជាការរាយការណ៍អំពីករណីចាប់រំលោភ ការផ្សាយអំពីជនរងគ្រោះដើម្បីស្វែងរកសេវាជួយអន្តរាគមន៍ ឬអំពីការឃាយីរំខានផ្សេងៗ។

អ៊ីនធឺណិត អាចជាឧបករណ៍ដ៏មានប្រយោជន៍មួយ ក្នុងការទទួលព័ត៌មានអំពីអំពើហិង្សាទាក់ទងនិងយេនឌ័រ ក៏ដូចជាការបំផុសការយល់ដឹងជុំវិញបញ្ហានេះជាសាធារណៈនិងតាមសហគមន៍។ ក្រៅពីនោះ ទូរស័ព្ទដៃ ផ្តល់ឱកាសដល់ស្ត្រីក្នុងការជៀសវាងអំពើជិះជាន់ការរំលោភបំពានកេងប្រវ័ញ្ចតាមរយៈការបើកការទំនាក់ទំនងជាមួយខាងក្រៅសម្រាប់ការងារធុរកិច្ច ចូលរួមក្នុងបណ្តាញសង្គម ព្រមទាំងអាចរាយការណ៍ឬអាចទទួលបានជំនួយអន្តរាគមន៍នៅពេលមានអំពើរំលោភបំពានកើតឡើង។ អ៊ីនធឺណិតនិងអ៊ីមែល ថែមទាំងអាចជាឧបករណ៍គៀង គរធនធានសម្រាប់ការងារតស៊ូមតិប្រឆាំងការរំលោភបំពានសិទ្ធិឯកជនឬរបស់ក្រុមណាមួយ។ Face book, Twitter ,blog និងOnline forum គឺជាឧបករណ៍ដែលគេនិយមប្រើសព្វថ្ងៃ។

ប្រព័ន្ធផ្សព្វផ្សាយសង្គម សំដៅទៅលើមធ្យោបាយនៃការផ្លាស់ប្តូរគ្នាក្នុងចំណោមមនុស្សទូទៅ នូវការបង្កើត ចែករំលែក ផ្លាស់ប្តូរព័ត៌មាននិងមតិយោបល់តាមរយៈបណ្តាញរបស់គេ។

បច្ចេកវិទ្យា គមនាគមន៍និងព័ត៌មានវិទ្យា ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថាជាឧបករណ៍គន្លឹះក្នុងការជួយបង្កលក្ខណៈងាយស្រួលដល់ការចូលរួមរបស់ជនក្រីក្រស្ត្រីនិងបុរសក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ព្រមទាំងជួយពួកគាត់ឲ្យចាកផុតពីភាពក្រីក្រ។

ទន្ទឹមនិងនោះ យើងឃើញថា ប្រព័ន្ធផ្សព្វផ្សាយសង្គមបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយផ្សព្វផ្សាយអំពីករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ យើងឃើញយុវវ័យបានប្រើ

ប្រាស់ច្រើននូវ ប្រព័ន្ធផ្សព្វផ្សាយសង្គម។ តែភាគច្រើននៃខ្លឹមសាគឺអំពីដំណើរកម្សាន្តឬអំពីម្ហូបអាហារដែលគេចូលចិត្ត។ តាមពិតទៅ ដូចបានជម្រាបជូនខាងលើប្រព័ន្ធផ្សព្វផ្សាយសង្គមគឺជាឧបករណ៍គន្លឹះដែលយើងអាចប្រើប្រាស់វាដើម្បីផ្សព្វផ្សាយអំពីគោលនយោបាយនិងច្បាប់នានាក្នុងការទប់ស្កាត់និងបញ្ឈប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ។

ទោះជាយ៉ាងណាយើងបានឃើញមានរឿងរាវជាច្រើនត្រូវបានផ្សព្វផ្សាយលើប្រព័ន្ធផ្សព្វផ្សាយដោយមានការគោរពភាពថ្លៃថ្នូរនិងជីវិតឯកជន ព្រមជាមួយគ្នានោះ សំឡេងស្ត្រីក៏ត្រូវបានគេឮច្រើន។

តែយើងត្រូវការឲ្យមានភាពសំបូរបែបថែមទៀត ចង់ឲ្យស្ត្រីបំបែកភាពស្ងៀមស្ងាត់និយាយឲ្យបានច្រើនជាង អំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ កុំចាំដល់រឿងកើតឡើងទើបនិយាយ យើងត្រូវផ្សព្វផ្សាយឲ្យបានច្រើនអំពីចំណាយសេដ្ឋកិច្ចនិងសង្គមទៅលើអំពើហិង្សាទាក់ទងនឹងយេនឌ័រ ចង់ឲ្យមានការកាត់បន្ថយផ្នត់គំនិតរើសអើងយេនឌ័រក្នុងសាច់រឿងដែលផ្សព្វផ្សាយ ព្រមទាំងត្រូវធានាថា អំពើហិង្សាទាក់ទងនឹងយេនឌ័រនៅតែជាព័ត៌មានក្តៅគគុកក្នុងកម្មវិធីដំណឹង។ នេះគឺជាភារកិច្ចរបស់យើងម្នាក់ៗ ទាំងអស់គ្នា។

ដើម្បីឆ្លុះបញ្ចាំងនូវបញ្ហាទាំងនេះ អង្គការវិទ្យាស្ថានបើកទូលាយ សហការជាមួយអង្គការAPC និងសម្ពន្ធភាពជាតិឃុំសង្កាត់ កំពុងអនុវត្តគម្រោង អំពី " អំពើហិង្សាទាក់ទងនឹងយេនឌ័រ" ដែលមានយុទ្ធនាការជំរុញការប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍និងព័ត៌មានវិទ្យាដើម្បីប្រយុទ្ធប្រឆាំងអំពើហិង្សាលើស្ត្រី។ យើងបានបង្កើតនិងដាក់ឲ្យប្រើប្រាស់ web site http://gbv.open.org.kh/ ជាវិប សាយមួយដែលលោកលោកស្រីអាចចូលទៅប្រើប្រាស់និងរាយការណ៍អំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ វិបសាយនេះមានផែនទីចង្អុលបង្ហាញករណី និងមានព័ត៌មានសេវាសង្គម ដែលអាចជួយជនរងគ្រោះបាន។នេះជាវិប សាយជាភាសាខ្មែរ ដែលលោកស្រីអស់លោក អាចចូលប្រើប្រាស់វាជាភាសាខ្មែរបាន។

ដើម្បីជំរុញដល់ការប្រើប្រាស់ បច្ចេកវិទ្យា សារគមនាគមន៍និងព័ត៌មានវិទ្យាឲ្យបានទូលំទូលាយ នោះ យើងក៏បានបង្កើតឡើងនូវបណ្តាញមួយមានឈ្មោះថា ICT4Development Cambodia Network http://ict4dcambodia.dsv.su.se/ ។ បណ្តាញនោះផ្តោតសំខាន់ទៅលើសិទ្ធិមនុស្ស ការអភិវឌ្ឍនិងអំពីលទ្ធិប្រជាធិបតេយ្យ។ សមាជិកបណ្តាញរួមមាន អង្គការវិទ្យាស្ថានបើកទូលាយ អង្គការ East West Management Institute, អង្គការមណ្ឌលព័ត៌មានស្ត្រីកម្ពុជា អង្គការInSTEED, APC និង SPIDER។

ឆ្លៀតឱកាសនេះ នាងខ្ញុំសូមថ្លែងអំណរគុណដល់ក្រសួងកិច្ចការនារី និងសម្ព័ន្ធភាព

ជាតិឃុំ សង្កាត់ ដែលតែងផ្តល់ការគាំទ្រដល់អង្គការវិទ្យាស្ថានបើកទូលាយ ដល់ស្ថាប័ននិង អង្គការសហការផ្សេងៗទៀតនិងដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំពោះការចូលរួមយ៉ាង សកម្មក្នុងគម្រោងនេះតាំងពីដើមដល់ចប់អស់រយៈពេលមួយឆ្នាំកន្លងមក។ នាងខ្ញុំក៏សូម ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អង្គការ Association for Progressive Communications (APC) និង The Swedish Program for ICT in Developing Regions (SPIDER) ចំពោះការឧបត្ថម្ភគាំទ្រផ្នែកហិរញ្ញវត្ថុ ធ្វើឲ្យគម្រោងនេះកើតឡើងនិងដំណើរការ ដល់ចប់ដោយជោគជ័យ។

មុននិងបញ្ចប់ នាងខ្ញុំសូមជូនពរ គណអធិបតី អស់លោក លោកស្រីដែលមានវត្ត មាននាពេលនេះ សូមប្រកបដោយសុខភាពបរិបូរណ៍ បញ្ញាវាងវៃ និងទទួលបានជោគជ័យ ក្នុងរាល់ការងារ។

សូមអរគុណ